# អ្វីទៅ ជា សន្ធិសញ្ញា

តាមខ្លឹមសារសន្ធិសញ្ញា (treaty) ត្រូវបានផ្តល់ន័យថា៖ *ជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលអនុម័តរវាងរដ្ឋជាលាយលក្ខអក្សរ និងគ្រប់គ្រងដោយច្បាប់អន្តរជាតិ ទោះបីក្នុងឯកសារតែមួយ ឬឯកសារពាក់ព័ន្ធច្រើន និង ក្នុងទម្រង់ជាក់លាក់ណាមួយក្តី*។[1] គ្រប់គ្រងដោយច្បាប់អន្តរជាតិ មានន័យថាបំពេញតាមទម្រង់ដែលតម្រូវ និងកម្មវត្ថុនៃកិច្ចព្រមព្រៀង មិនត្រូវផ្ទុយនឹងវិធានច្បាប់អន្តរជាតិ។

ក្នុងន័យនេះមិនមែនលុះត្រាតែឈ្មោះ ឯកសារ ជាសន្ធិសញ្ញា ទើបគេហៅថាសន្ធិសញ្ញាទេ។ វាអាចមានឈ្មោះជា កិច្ចព្រមព្រៀង (agreement) អនុសញ្ញា (convention) កតិកាសញ្ញា (covenant) កិច្ចព្រមព្រៀងបញ្ចប់ជម្លោះ (pact) អនុស្សរណៈយោគយល់គ្នា (Memorandum of Understanding: MoU) ឬពិធីសារ (protocol)។[2] អ្វីដែលសំខាន់គឺខ្លឹមសារនៃឯកសារ បង្កើតជាសិទ្ធិ និងកាតព្វកិច្ចដែលនាំឲ្យគេ ចាត់ថាជាសន្ធិសញ្ញា។ "សន្ធិសញ្ញា" គឺជាពាក្យ ទូទៅ។ គេអាចកត់សំគាល់ទៀតថា ជួនកាល ការដាក់ឈ្មោះ លើឯកសារណាមួយ ជាអ្វីធ្វើឡើងតាមការដែលភាគីឯកភាពចង់បាន។

សន្ធិសញ្ញា ឬ កិច្ចព្រមព្រៀង ត្រូវបានចាត់ជាទ្វេភាគី[3] (bilateral) ឬពហុភាគី[4] (multilateral) ដែលខាងក្រោយនេះមានកម្រិតសកល[5] (universal) ឬតំបន់[6] (regional) និងតាមវិស័យជាក់លាក់ណាមួយ ឬទូទៅ[7]។

---

[1] (a) "treaty" means an international agreement concluded between States in written form and governed by international law, whether embodied in a single instrument or in two or more related instruments and whatever its particular designation; United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 2 July 2019] (VCLT).

[2] Duncan B. Hollis, ed., The Oxford Guide to Treaties, 2012, Defining Treaties, p. 11.

[3] Treaty on Extradition between Pakistan and the United Kingdom, 1935.

[4] UN General Assembly, *Convention on the Rights of the Child*, 20 November 1989, United Nations, Treaty Series, vol. 1577, p. 3, available at: https://www.refworld.org/docid/3ae6b38f0.html [accessed 4 July 2019.

[5] United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html [accessed 4 July 2019] UN Charter

[6] African Charter on Human and People's Rights (Banjul Charter), Organization of African Unity (OAU), *African Charter on Human and Peoples' Rights ("Banjul Charter")*, 27 June 1981, CAB/LEG/67/3 rev. 5, 21 I.L.M. 58 (1982), available at: https://www.refworld.org/docid/3ae6b3630.html [accessed 4 July 2019].

[7] UN General Assembly, *Convention on the Rights of Persons with Disabilities : resolution / adopted by the General Assembly*, 24 January 2007, A/RES/61/106, available at: ttps://www.refworld.org/docid/45f973632.html [accessed 4 July 2019].